នាងដើរកាត់ហាងផ្កាធំមួយ...រស់នៅដូចប្ដីប្រពន្ធជាង២ឆ្នាំហើយ ឆ្លងកាត់រឿងកម្សត់ជាច្រើនជាមួយគ្នា...ផ្កាមួយបាច់ក៏គេមិនដែលទិញជូននាងផង...ថ្ងៃនេះ...

---

មួយរយៈនេះ មេឃងងឹតចម្លែកៗ...គ្មានព្រះអាទិត្យទេ!

រឿងរ៉ាវមួយនេះបានកើតឡើងនៅពេលនាងកំពុងតែខូចចិត្ត ដែលសង្សាររួមរស់ជាមួយគ្នាត្រូវរៀបការជាមួយមនុស្សស្រីថ្មី។ គ្រប់យ៉ាងអាចថាដោយសារតែមនុស្សស្រីនោះមានអ្វីគ្រប់យ៉ាង ឬអាចហៅម្យ៉ាងទៀតថា ផ្ញើបេះដូងប៉ះប្រុសក្បត់។

គេចាកចេញទៅទុកនាងឱ្យរស់នៅតែបន្ទម្នាក់ឯងឯកោ នៅក្នុងបន្ទប់ជួលដែលធ្លាប់កសាងគ្រួសារដោយគ្មានខាន់ស្លានៅពីរនាក់គេ។

«កុសមា! មានគេផ្ញើផ្កាមកបងឯង!»

សំឡេងអាចូចកូនមីងចាន់ដែលលក់កាហ្វេនៅមុខផ្លូវ។

ផ្កា? អ្នកណាជូនទៅ?

កុសុមាក៏នឹកឃើញភ្លាមដល់នាយសុខធន ដែលជាសង្សារធ្លាប់រួមរស់ជាមួយគ្នា។ អ្នកនៅម្តុំនេះនរណាក៏ស្គាល់គេដែរ បើសិនជាគេជាអ្នកផ្ញើមក ច្បាស់ជាមានឈ្មោះគេនៅពេលអាចូចប្រាប់មកអម្បាញ់មិញហើយ។

ព្រោះនេះជាថ្ងៃចុងក្រោយដែលកុសុមារៀបចំរើអីវ៉ាន់ចាកចេញពីកន្លែងអនុស្សាវរីយ៍ដ៏កម្សត់នេះ គ្រប់គ្នាប្រហែលជាចង់លួងលោមនាងក៏ស្រាក់លុយគ្នាទិញមកជាបាច់ផ្កានេះដឹង?

នាងខំញញឹមធ្វើពើ រៀបរយខោអាវ រួចបើកទ្វារមកក៏ឃើញផ្កានៅលើកៅអីថ្ម ដែលម្ចាស់ផ្ទះដាក់ឱ្យសម្រាប់អង្គុយលេងប្រឋផ្លូវ។

ឯណាអាចូច?

អត់ឃើញមនុស្ស! ចំណែកក្រឡេកឃើញបាច់ផ្កាធំនេះកាលណា នាងចាប់អារម្មណ៍ចម្លែកភ្លាម! មើលទៅមិនសមថាអ្នកផ្ទះជួលម្តុំនេះអាចមានលទ្ធភាពទិញវាមកឱ្យនាងនោះទេ បើពួកគេចង់លើកទឹកចិត្តនាងដែលឈឺចាប់ស្ទើរស្លាប់ ក៏ពួកគេមិនមានលុយឬមិនស្គាល់ហាងដែលអាចក្រងបាច់ផ្កាបានស្អាតកម្រិតនេះដែរ។

ដោយទឹកមុខងឿងឆ្ងល់ជាខ្លាំង នាងត្រកងបុស្បាចូលបន្ទប់។

«បន្ទប់លេខដប់បី!»

ច្បាស់ហើយមិនច្រឡំបន្ទប់ទេប្រសិនពិនិត្យតាមកូនក្រដាសតូចសរសេរលើនេះ។

នាងធូរចិត្តដែលទទួលបាច់ផ្កាមកត្រូវលេខបន្ទប់ ទោះមិនដឹងនៅឡើយថាអ្នកណាជាម្ចាស់វា! មិនទាន់បង្វិលខ្លួនចូលមកដល់ក្នុងបន្ទប់ត្រឹមត្រូវផង កុសុមាភ្ញាក់ព្រើតរបូតផ្កាពីដៃ...នាងស្លុយនឹងអ្វីម្យ៉ាងចម្លែកនៅលើទងបុប្ផាទាំងនោះ...ឈាម?

មិនមែនពណ៌ក្រហមទេតែវាជាមក្រហមព្រោះឈាម!

ឈាមចាប់ផ្ដើមហូរ...នាងក៏រត់...

---

តាំងពីពេលដែលទទួលបានបាច់ផ្កាប្រឡាក់ឈាមគួរឱ្យភ័យខ្លាចនោះ កុសុមាបានចាកចេញមកជាមួយវ៉ាលីសកម្បត់របស់នាង ដោយបោះចោលអ្វីៗជាច្រើនដែលជាអនុស្សាវរីយ៍ជាមួយនឹងសង្សារហេងស៊ុយធ្លាប់រួមរស់ជាប្ដីប្រពន្ធកើតចង្ក្រានចានឆ្នាំងជាមួយគ្នានៅលើផ្ទះជួលជាងពីរឆ្នាំ។

នាងមិនអាចបន្តនៅបន្ទប់ជួលនោះទៀតទេ។ កន្លែងនាងរស់នៅគឺជាន់ទីបួននៅប្លុកមួយចំកណ្ដាលក្រុងភ្នំពេញ គឺម្ដុំបឹងត្របែកដែលជាបណ្ដុំទៅដោយអាផាតមិន។

អាផាតមិននេះតាមពិតមានបីបន្ទប់។ នាងជួលចូលគ្នាជាមួយអ្នកធ្វើការពីរនាក់ទៀត។ ពីរនាក់ទៀតមានម្នាក់ជាធ្វើការខាងនាំភ្ញៀវទេសចរគាត់មិនសូវនៅផ្ទះទេ គាត់ឈ្មោះថាមុំ អាយុបងកុសុមាដល់ទៅប្រាំពីរឆ្នាំ ប៉ុន្តែម្នាក់ទៀតគឺជាមិត្តភក្ដិតាំងពីរៀនជាមួយគ្នានិងបានធ្វើការជាមួយកុសុមាឈ្មោះថា ស្រីមាន។

ស្រីមានធ្វើការជាមួយកុសុមាកាលមុនកូវីដ ក្រោយមកនាងក៏ផ្លាស់ទៅធ្វើការកន្លែងផ្សេង ប៉ុន្តែពួកគេនៅតែរាប់អានគ្នា។ ហើយបន្ទប់នាងសល់មួយ ដូច្នេះនាងក៏ចែកវាមកឱ្យកុសុមាពេលដឹងថាមិត្តកំពុងបាត់បង់ស្នេហា។

ដ្បិតអាផាតមិននេះមានបន្ទប់បី ប៉ុន្តែវាតូចខ្លាំងណាស់ដូច្នេះការរស់នៅរបស់រាងចង្អៀតបន្តិច គឺបើបងមុំមកដល់  នាងចេញមកគេងនៅលើបន្ទប់សាឡុង ពីព្រោះបីបន្ទប់នេះមានបន្ទប់គេងតែពីរទេ ទីបីគឺបន្ទប់សាឡុង។ ពេលនេះនាងកំពុងគេងក្នុងបន្ទប់គាត់ទាំងថ្ងៃព្រោះហត់ល្វិតល្វៃដៃជើងយ៉ាងចម្លែក។

តុកតុកតុក

កុសុមា ស្រែកសួរៈ

«អ្នកណា?!»

«មានគេផ្ញើបាច់ផ្កាមកជូនបងឯង!»

អារម្មណ៍កុសុមាក្តុកក្តួលភ័យ ពេលនឹកឃើញផ្កាបាច់ប្រឡាក់ឈាមឆ្នៅឆ្អិនកាលនៅឯបន្ទប់ជួល។ នាងបើកទ្វារភ្លាម ព្រោះស្គាល់ថាជាកូនប្រុសវ័យជំទង់ម្នាក់របស់អ្នកយាមនៅជាន់ក្រោម។ តែពេលចេញមកគ្មានមនុស្សទេ ឃើញតែខ្នងមនុស្សរត់ចុះជណ្តើររកមើលមិនទាន់។ ចំណែកបាច់ផ្កាត្រូវបានដាក់បញ្ឈរក្បែរទ្វារចោល។ ផ្កានេះធំជាងមុនទៀត ប៉ុន្តែជាផ្កាប្រភេទដដែលដូចកាលដែលនាងបានឃើញនៅឯផ្ទះជួលពីប្រមាណជាជាងមួយសប្តាហ៍មុន។

បេះដូងកុសុមាភ័យខ្លាំង ប៉ុន្តែផ្កាពិតជាស្រស់ពេកហើយមិនសមធ្វើមិនឃើញទេ។

ក្រដាសសលើនោះសរសេរថា កុសមា អាផាតមិនជាន់ទីបួន។

មាណវីយើង លូកដៃសន្សឹមៗទៅទទួលវាយកមកមើលពិនិត្យមើលចុះឡើង ឃើញថាមិនមានឈាមមិនមានអ្វីទាំងអស់ ក៏យកមកដាក់លើតុបាយហើយបិទទ្វារទៅវិញ។

មិត្តភក្តិរបស់នាងត្រលប់មកផ្ទះពេលថ្ងៃត្រង់រាល់ដងដើម្បីញ៉ាំបាយនិងសម្អាតខ្លួន។ ស្រីមានស្រែកវ៉ាសពេលឃើញផ្កាធំមួយបាច់នេះ។

«មានសង្សារទៀតហើយ?»

«មានហ្អា!» កុសុមាបដិសេធដោយទឹកមុខឆ្ងល់ ហើយនិយាយបន្តទៀតថា

«មិនដឹងអ្នកណាទេ យើងឆ្ងល់ណាស់» ស្រីមានឮហើយសម្លឹងមុខមិត្តថានិយាយមែនឬក៏លេង។ មិនតែប៉ុននោះនាងដើរមកឱនពិនិត្យមើលបាច់ផ្កាទាំងធ្វើមុខស្ញប់ស្ញែងហើយនិយាយឡើងថាៈ

«ថ្លៃណាស់ផ្កានេះ! សង្សារចាស់របស់ឯងហើយមើលទៅ? គេមានប្រពន្ធជាអ្នកមានដែលបេះដូងគេមិនត្រូវការ ឥឡូវមានលុយច្រើនពេកទំនេរៗក៏នឹកឃើញដល់ឯង ចង់វិលលួចលាក់!»

«កុំនិយាយរឿងអពមង្គលគ្មានថ្ងៃទេ!»

កុសុមាប្រកែកហើយចូលទៅក្នុងបន្ទប់ ស្រីមានតាមមើលមិត្តដោយឆ្ងល់ រួចបែរចូលទៅងូតទឹកធ្វើព្រងើយ។

នៅក្នុងបន្ទប់ កុសុមានៅអង្គុយស្ងៀមធ្វើភ្នែកភ្លឹះៗសម្លឹងជញ្ជាំងទាំងគិតម្នាក់ឯងបែកខ្ញែកថា៖

«អាចថា អ្នកផ្ទះនោះបានយកសង្សារខ្ញុំទៅ ហើយព្រមានខ្ញុំកុំឱ្យពាក់ព័ន្ធជាមួយប្ដីរបស់គេទេដឹង លើកមុនមានដាក់ឈាមលើផ្កា ប៉ុន្តែលើកនេះគ្មានទេ! ហេតុអីបានជានៅតាមបន្លាចធ្វើទុក្ខបុកម្នេញខ្ញុំទៀត?»

នាងហត់ណាស់ មានអារម្មណ៍ថាមួយរយៈនេះមិនចង់ចេញដើរ គឺហត់ៗនៅសុំច្បាប់គេគេងសម្រាកខូចចិត្តនៅឡើយ។

ភ្លាមនោះកុសុមាដូចបានឮសូរអ្វីម្យ៉ាង ជាសំឡេងមនុស្សសើច។ នាងខំផ្ទៀងស្ដាប់ ក្រែងស្រីមាននិយាយទូរសព្ទ តែមិនមែនទេជាសំឡេងប្រុស។

ដូច្នេះទ្រាំមិនបាន នាងក៏ដើរចេញមករកមើល។

មិនឃើញអ្វីទាំងអស់គ្មានអ្នកណាទេស្រីមាននៅងូតទឹកឈូៗនៅឡើយក្នុងបន្ទប់ទឹក។

ចៃដន្យក្រឡេកទៅឃើញបាច់ផ្កា នាងក៏ផ្ដោតសម្លឹងឡើងវិញ។ បាច់ផ្កានេះមានបង្កប់ខ្សែអាត់សំឡេងឬក៏យ៉ាងម៉េច បានជាអម្បាញ់មិញឮសំឡេងមនុស្សប្រុសសើច?

អត់ទេ! ចម្លែកម៉េះ?

ភ្លាមនោះ ត្រឹមមួយក្រឡេកចុងក្រោយនាងឃើញឈាម!

ពុទ្ធោអរហំ! ឈាមទៀតហើយ?

បេះដូងកុសុមាសឹងគាំងៗពិតមែន! គឺឈាមពោរពេញស្រោចស្រពពីលើបាច់ផ្កានេះ  ដូចវាចេះផលិតឈាមជ្រាតចេញមកពីកេសរនីមួយៗដែរ។

ស្រីស្រស់រូបនេះហាមាត់ស្រែក នាងស្រែក! ស្រែក! អស់មួយទំហឹងតែម្ដងប៉ុន្តែស្រែកយ៉ាងណាក៏ស្រីមាន នៅឯបន្ទប់ទឹកហាក់គ្មានប្រតិកម្មនិងដូចជាសម្រែកមិនឮអ្វីទៅដល់នោះដែរ។

ស្លន់ពេក ស្រីកុសុមាលោតទៅលើសាឡុងខ្ទប់ត្រចៀកដោយខ្លួនឯង។

គ្រប់យ៉ាងដូចជាកើតឡើងលើនាងតែម្នាក់ឯង ស្រីមាននៅតែមិនចេញពីបន្ទប់ទឹកមកសោះ។ គេមិនដែលងូតទឹកយូរដល់ម្លឹងទេ ។

ទាំងក្ដីតក់ស្លុតខឹងសម្បារនាងក្រោកទៅទាំងកំហឹងទាញស្រវាយកបាច់ផ្កាគ្រវាត់បោះចោលពីជាន់ទីបួនដល់ជាន់ខាងក្រោម។

---

ចាប់តាំងពីពេលដែលមានរឿងបាច់ផ្កាប្រឡាក់ឈាមលើកទីពីរនោះមក នាងក៏មិនបាននិយាយអ្វីជាមួយស្រីមានច្រើនដែរ គ្រាន់តែពេលគេចេញមក គេក៏មិនបានឱកាសសួរនាងថា បាច់ផ្កាបាត់ទៅណាហើយទេព្រោះកុសុមាសំងំយំម្នាក់ឯងក្នុងបន្ទប់។

នាងចាក់សោទម្រាំស្រីមានចេញទៅធ្វើការបាត់ ទើបនាងចេញមកចុចទូរសព្ទទៅម្ដាយ។

ចុចយ៉ាងណាគ្មានអ្នកលើកសោះ!

នាងពិបាកចិត្តបាយមិននឹកទឹកមិនស្រេក ក៏ប្រះគេងលក់លើសាឡុងម្នាក់ឯង។ មិនយូរទេ ត្រឹមមួយភ្លែតប៉ុននោះ កុសុមាក៏ស្រមៃឃើញមនុស្សប្រុសម្នាក់បើកទ្វារចូលមក។ មុខគេដែលបែរមកកាលណានាងពិតជាមិនដែលស្គាល់ទាល់តែសោះ។

ទោះបីគ្មានសញ្ញាណថាជាឧក្រិដ្ឋជនឬចោរ តែនាងខំស្រែករកជំនួយនិងសួរថាគេជានរណាមកធ្វើអ្វីក្នុងអាផាតមិននេះ តែសំឡេងនាងមិនលាន់ចេញសោះ។ ប្រុសនោះមកដល់ក្បែរនាងខណៈនាងនៅជាប់គាំងក្រោកទៅណាមិនរួច។ ដោយក្ដីភ័យខ្លាច នាងឃើញគេនោះលូកដៃមកអង្អែលថ្ពាល់នាងនិងផាត់សក់នាង។

«ចេញទៅៗៗ»

នាងស្រែកបែបនេះរហូតដល់ដឹងខ្លួនមកវិញ ឃើញខ្លួនឯងគេម្នាក់ឯងងងឹតស្លុបកប់ព្រលប់ហើយ។ ចាប់ពីពេលនោះមកកុសុមាសែនខ្លាច។

នាងមិនចង់គេងទេ អ្វីមួយចម្លែកៗកើតមានចំពោះជីវិតរបស់នាង។ មនុស្សដដែលនោះបង្ហាញខ្លួនជានិច្ចរាល់ពេលនាងគេងមិនថាយប់ឬថ្ងៃ ដោយមកឱបត្រកង ចួនដោះអាវនាង ថើបនាង។ មានថ្ងៃខ្លះក៏យល់សប្តិឃើញរួមភេទជាមួយគ្នាទៀតផង។

ការណ៍នេះកើតឡើងជារឿយៗ តែនាងរើបម្រះមិនបានរហូតដល់កុសុមាចាប់ផ្ដើមចម្លែកចិត្តដោយខ្លួនឯងថាតើនាងអាចមានរោគចិត្តធ្ងន់ធ្ងរដល់វិកលព្រោះនៅនឹកសង្សារចាស់ពេកទេដឹង?

ទឹកមុខនាងឡើងខ្មៅជាំពេលងើបមកសម្លឹងខ្លួនឯងក្នុងកញ្ចក់។ ភ្នែកនេះខូងដូចជាមិនបានគេង។

ស្រីមានចេញទៅធ្វើការបាត់ៗ ចំណែកបងមុំនៅតែអត់ឃើញមក។

នាងនៅផ្ទះម្នាក់ឯងទៀតហើយទាំងពិបាកចិត្តខ្លាំង ក៏មកអង្គុយត្របោមជង្គង់ចុចទៅរកម្ដាយនៅស្រុកទៀត។ ទោះមិនចង់ឱ្យគ្រប់គ្នា ឬប្រពន្ធថ្មីរបស់សុខធនមើលងាយថា នាងខ្ញុំត្រូវបានឆ្កួតអសារដោយសារតែបាត់បង់មនុស្សប្រុសគ្មានតម្លៃម្នាក់នោះ តែប៉ុន្មានថ្ងៃនេះនាងចេះតែគិតថា ខ្លួនឯងហាក់ត្រូវបានអ្នកណាម្នាក់ជាមនុស្សប្រុសមកលងបន្លាចក្នុងសុបិនមិនលោះសោះ នាងចង់ប្រាប់អ្នកផ្ទះគ្រប់រឿងអ្វីៗកើតឡើងចំពោះនាងរកដំណោះស្រាយច្បាស់លាស់ថា ជាអារម្មណ៍នាងដែលខូចចិត្តពេក ឬអាជាតមិននេះមានខ្មោច?

ទូរសព្ទនៅតែគ្មានអ្នកលើក តើមានអ្វីកើតឡើងចំពោះគ្រួសារនាងនៅស្រុក?

កុសុមាកើតចិត្តនឹកពិភាល់មិនល្អខ្លាំងណាស់។ នៅមិនសុខនាងក៏ចុចទៅរកស្រីមុំម្ចាស់បន្ទប់នេះម្ដង ព្រោះគាត់ចាស់ទុំជាងអាចថាពិគ្រោះជាមួយគាត់ក៏ល្អ។ លើកនេះមានគេលើកទទួល។

«អាឡូ! រកអ្នកណា?!»

«ខ្ញុំមិត្តភក្តិបងមុំ ដែលជួលបន្ទប់នៅភ្នំពេញជាមួយគាត់ សុំជួបគាត់បន្តិច!»

«ឈប់ខលមកទៅ កុំលេងរបៀបនេះ!»

អ្នកនោះឆ្លើយបានប៉ុន្មានម៉ាត់ប៉ុណ្ណឹងហើយក៏ផ្ដាច់ចោលភ្លាម ធ្វើឱ្យកុសុមាឆ្ងល់អនេក។ នាងចង់ចុចទៅសួរនាំទៀត ព្រោះនៅឆ្ងល់ខ្លាំង ប៉ុន្តែក៏ចុចលែងចូល។ មិនអស់ចិត្តទើបនាងរាវរកលេខក្រុមហ៊ុនទេសចរនោះបាន រួចខលទៅរកលេខទូរសព្ទលើតុ។

«ជម្រាបសួរ ខ្ញុំចង់សួរថាបងមុំដែលនាំភ្ញៀវទៅខេត្ត គាត់ថ្ងៃណាមកវិញ?!»

អ្នកលើកនោះមិនឆ្លើយទេ ស្ងាត់បន្តិចក៏ដាក់ទូរសព្ទចុះចោលគ្រឹប។

នាងនៅទ្រឹងនឹងរឿងចម្លែកៗអស់ទាំងនេះ។

មិនយូរប៉ុន្មាន កណ្ដឹងរោទ៍ម្ដង...គឺកណ្ដឹងទ្វារ...

ដោយសារពេលនេះនៅម្នាក់ឯង កុសុមាត្រូវក្រោកទៅបើកទ្វារទាំងអស់កម្លាំងខ្លាំង ប្រសិនស្រីមាននាងពិតនៅខាងក្រោម។

គ្មានអ្នកណានៅក្រៅទេ?

ហួសចិត្តណាស់! កុសុមាញីថ្វាសលែងយល់ពីខ្លួនឯង!

បិទទ្វារមកវិញគ្រឹបភ្លាម នាងក៏ត្រលប់មកក្នុងវិញ ទាំងគិតថាជំងឺសសៃប្រសាទអាចដល់ថ្នាក់បណ្ដាលឱ្យស្រមៃទាំងថ្ងៃបានទៀត?

«ហើយបើសិនជាខ្ញុំត្រូវអំពើអ្នកណាម្នាក់ ប្រាកដណាស់ជាអំពើរបស់ប្រពន្ធថ្មីរបស់ប្រុសសាវ៉ា សុខធននោះហើយ! ដឹងថាប្ដីដែលត្រូវឆក់ទៅបានដោយសារលុយ មិនមែនដោយបេះដូងគេនៅតែច្រណែនខ្ញុំ មិនមែនខ្ញុំត្រូវច្រណែនគេឡើយ!»

គិតដូច្នេះហើយងាកត្រលប់មកវិញ កុសុមាភ្ញាក់សឹងដួលសន្លប់ព្រោះបាច់ផ្កាមួយបាច់រូបរាងដដែលបានផុសឡើងនៅលើតុបាយចំកន្លែងដែលនាងធ្លាប់ដាក់វាកាលពីប៉ុន្មានថ្ងៃមុន។

ស្រីពិតជាត្រូវញ័រដៃញ័រជើងអស់កំលាំង សូម្បីតែនឹងដួលសន្លប់ក៏មិនមានកម្លាំងដួលបានផង។

«អ្នកណាម្នាក់រួមដៃគ្នាលេងសើចជាមួយខ្ញុំឬក៏យ៉ាងម៉េច? មានតែអាមាន ឬបងមុំទេទើបមានសោចូលបន្ទប់នេះ ឬមួយក៏បងមុំពញ្ញាក់?»

នាងរត់ទៅមើលបន្ទប់ផ្សេងទៀតគ្មាននរណានៅនោះទេ។

នាងភ័យស្លុត ហើយស្រវាបើកភ្លើងឡើងទាំងអស់ដើម្បីខំបំភ្លឺអាផាតមិននេះទាំងមូល តែពន្លឺអគ្គិសនីនៅតែភ្លឺមិនស្រឡះសោះ ស្លុងៗម៉េចមិនដឹង។

ដោយភាពថប់បារម្ភ កុសុមាក្រឡេកសន្សឹមៗទៅរកបាច់ផ្កា។ ដូចស្រីកម្សត់ស្មានមិនខុសទេ មិនយូរប៉ុន្មានតំណក់ឈាមស្រស់ៗហូរចេញមកពីស្រទាប់ផ្កានីមួយៗ។ នាងខ្ញុំទះមុខខ្លួនឯងហើយស្រែកថាខ្ញុំកំពុងយល់សប្ដិ គឺកំពុងតែឆ្កួត ខ្ញុំឆ្កួតហើយ!

នាងស្រែក! ស្រែក! ស្រែក! ស្រែកអស់ពីបេះដូង ប៉ុន្តែស្ងាត់សូន្យ គ្មានអ្នកជិតខាងឬសន្តិសុខណាម្នាក់រត់ឡើងមកមើលទេ ប្រៀបបីដូចជាកុសុមារស់ក្នុងលោកនេះតែម្នាក់ឯង។

នាងខំរត់ទៅរកទ្វារ តែទាញមួលបើកសោទ្វារមិនចេញ ទាញទ្វារបើកមិនកើតទាល់សោះ។ ទីបំផុតនាងក៏ទន់ជង្គង់នៅទីនោះតែម្ដង។

ពេលកុសុមាភ្ញាក់ដឹងខ្លួនឡើង គឺឃើញខ្លួនឯងកំពុងគេងលើគ្រែក្នុងបន្ទប់របស់បងមុំ។

មនុស្សប្រុសម្នាក់កំពុងតែអង្គុយក្បែរនាងហើយលូកដៃមកអង្អែលថ្ពាល់នាង។

ដោយម្ដងៗកុសុមាស្រែកយំថា អ្នកជាអ្នកណា? ហេតុអីខ្ញុំយល់សប្ដិឃើញអ្នកឯងដដែលជាដដែល? មនុស្សប្រុសម្នាក់នោះនិយាយប្រាប់ថា ខ្ញុំជាសារ៉ាវិទ្ធ ជាសង្សារចាស់របស់ឯង ចាំបានទេកុសុមា។

នាងគ្រវីក្បាលតតាត់ថា ខ្ញុំគ្មានសង្សារទេ! គេនោះនៅតែប្រកែកជាមួយនាងថា នាងជារបស់គេ។

«ក្រៅពីបងសុខធន ខ្ញុំមិនដែលរួមរស់ជាមួយមនុស្សប្រុសណាឡើយ!»

ឮដូច្នេះហើយគេខឹងនាងខ្លាំង បើកភ្នែកក្រឡោតៗ លូកដៃមកច្របាច់កនាងអស់ចិត្តទើបស្ទុះមកគ្របពីលើនាងនិងបង្ខំរួមភេទ។ ដំបូងនាងប្រកែកនឹងស្រែកយំតែ មិនអាចទទួលជោគជ័យបានរួចក៏លិចលង់ទៅក្នុងការបបោសលួងលោមដោយកាមារបស់គេទាំងស្រុង ហើយដូចរាល់ដងដែរគឺកុសុមាគេងលក់ដូចប្ដីប្រពន្ធជាមួយនឹងបុរសម្នាក់នោះ។

ព្រឹកឡើងនាងភ្ញាក់ដឹងខ្លួនក៏ឃើញខ្លួនឯងកំពុងតែដេកស្តូកស្តឹងឯកោដដែល។

នាងដឹងថាមេឃភ្លឺហើយ ចំណែកប្រុសម្នាក់នោះប្រាកដជាខ្មោច។

នាងស្រវេស្រវាក្រោកឡើងទាំងបង្ខំ ឃើញស្រីមាននិងបងមុំអង្គុយបែរខ្នងហូបអាហារពេលព្រឹក។

«ខ្ញុំទៅស្រុកហើយ ខលម៉ែច្រើនដងមិនចូលសោះ!»

បាច់ផ្កាប្រឡាក់ឈាមនោះមិនបាននៅទីនោះទេ គ្រប់យ៉ាងគឺជាយល់សប្ដិ។ ពួកគេក៏បន្តញ៉ាំអាហារ មិនមាត់តបអ្វី ឯនាងមិនខ្វល់អ្វីជាមួយពួកគេទេ ទាំងអារម្មណ៍ខ្លួនឯងមិននឹងនរឡើយ។

នៅតាមផ្លូវជិះឡានឈ្នួលទៅស្រុក នាងរកនឹកពីមនុស្សដែលប្រាប់ថា គេឈ្មោះសារ៉ាវិទ្ធ។ ការរួមភេទជាមួយគេបន្សល់នូវអនុស្សាវរល្អឡើងៗ នាងស្រាប់តែនឹកដល់គេ ចង់រកនឹកឱ្យច្បាស់ថាហេតុអ្វីនាងយល់សប្ដិបែបនេះជាមួយគេ?

ចុងក្រោយនាងក៏នឹកឃើញ។ រឿងយូរណាស់ហើយកាលនៅវ័យជំទង់ អាយុប្រហែលជាដប់ប្រាំឆ្នាំមានក្មេងប្រុសម្នាក់អាយុប្រហែលស្របាលគ្នា បានប្រាប់មិត្តភក្តិរបស់គេពេញសាលាថា ស្រឡាញ់កុសុមា។

ថានាងមិនចេះស្រឡាញ់ប្រុសទេ ឮដល់ត្រចៀកក៏ខឹងណាស់ ព្រោះកុសុមាមិនដែលស្គាល់អ្វីដែលហៅថាសេចក្ដីស្នេហាឡើយ។

គេនោះរៀនថ្នាក់ជាមួយនាងដែរ ជាមនុស្សទុះមុះទុយមុយ មិនសូវមាត់មិនសូវក ហើយឮថាគេជាកូនអ្នកខេត្តផ្សេង ដូច្នេះហើយពួកនាងមិនដែលនិយាយរកគ្នាសូម្បីបានម្ដង អាងអីហ៊ានមកពោលស្នេហា?

ការដើរប្រាប់គេឯងថាជាសង្សារនឹងគ្នា មិនបានចប់ទេ នៅតែបញ្ឆេះចិត្តនាងជារៀងរាល់ថ្ងៃ រហូតដល់ទ្រាំលែងបាន ថ្ងៃមួយនាងឃើញគេមកដល់ក្បែរម៉ូលក់នំចំណីសម្រាប់សិស្ស នាងកំពុងស្ថិតនៅក្នុងចំណោមជាមួយមិត្តភក្តិស្រីៗភាគច្រើនដែលនិយមបង្អាប់នាងជាសង្សារគេនោះនាងក៏ស្រែកឡូឡាស្ដីឱ្យប្រុសជំទង់នោះថា

«ឯងឈប់តាមខ្ញុំទៀត ហើយឈប់ស្រមៃរឿងស្នេហាជាមួយខ្ញុំ ខ្ញុំមិនដែលស្រឡាញ់សារ៉ាវិទ្ធឯងទេ ចាំខ្ញុំស្លាប់សិន ចាំដើរនិយាយប្រាប់គេពេញសាលាថាយើងជាសង្សារនឹងគ្នា! ខ្ញុំស្អប់ខ្លាំងណាស់!»

នឹកឃើញអស់ហើយ នាងហាក់ភ័យខ្លួនយ៉ាងខ្លាំងនឹកឃើញនូវអ្វីគ្រប់យ៉ាងទាក់ទងជាមួយមនុស្សប្រុសក្នុងសុបិនដែលប្រាប់ថាខ្លួនឯងឈ្មោះសារ៉ាវិទ្ធ ហើយនិងរកនឹកថា ជាមនុស្សតែមួយឬយ៉ាងណា?

ឥឡូវនេះនាងមានវ័យចូលជិតសាមទៅហើយ។

រយៈពេលយូរយ៉ាងនេះ តើកុសុមាចំណាំរូបរាងគេម៉េចនឹងបានទៅ?

ដឹងខ្លួនពីលក់មួយភាំង ឡានស្រាប់តែឈប់កណ្ដាលផ្លូវ គឺមិនឆ្ពោះមកស្រុកកុសុមាដូចនាងគ្រោងទេ។

ពេលបើកភ្នែកមមិងមមាំង ក៏ឃើញខ្លួនឯងបានជិះនៅលើឡានសំដៅទៅស្រុកកំណើតតែមានតែម្នាក់ឯងគត់ អ្នកផ្សេងមិនដឹងចុះអស់តាំងពីថ្មើរម៉ាន?

នេះជាស្លាកផ្លូវខេត្តកំពង់ចាមចាំបានថានាងមិនបានមានគម្រោងមកកំពង់ចាមទេ។

ឡានគ្មានតែកុង គ្មានអ្នកណាទាំងអស់ បើមិនចុះតើនៅធ្វើអី?

នាងឃើញកូនផ្ទះមួយដូចជាធ្លាប់ស្គាល់នៅម្ខាងផ្លូវពីទីនេះ។

មនុស្សប្រុសម្នាក់បង្ហាញខ្លួននៅមាត់របង គឺមនុស្សប្រុសឈ្មោះសារ៉ាវិទ្ធ ក្នុងការចងចាំរបស់នាងដែលបានគេងប្រលោមនាងដូចប្ដីទៅហើយ។

គេនោះឆ្លងមកដឹកដៃនាងទៅ។

នាងឆ្ងល់ណាស់ តើនាងបានព្រមមករកគេដល់ស្រុកកំណើតពីពេលណាទៅ ម៉េចនាងភ្លេចអស់អ៊ីចឹង?

គេរុញរបងចូល!

វាគឺជាគេហដ្ឋានមួយដែលបង្ហាញពីជីវភាពធូរធាររបស់អ្នកខេត្តកំពង់ចាម មានរបងព័ទ្ធជុំវិញ ថ្មក្រោមឈើលើប៉ុន្តែជាប្រភេទឈើមានតម្លៃ និងមានសួនច្បារស្រស់បំព្រងដូចជាមានអ្នកថែទាំ ច្បាស់លាស់។

«ទីនេះជាកន្លែងអ្វី?»

«ផ្ទះរបស់ពួកយើង! ភ្លេចហើយ?»

ពេលនោះមេឃព្រលប់ៗហើយ។ កុសុមាញីក្បាលនាងពិតជាងោកងុយណាស់ថែមទាំងគិតមិនឃើញថាហេតុអីមកកន្លែងនេះ «ភ្លេច» ដែលគេកំពុងសួរនេះគឺភ្លេចអ្វី?

«ខ្ញុំទៅស្រុកខ្ញុំ!»

«ទេ កុសុមាមករួមរស់កន្លែងនេះ!»

មាណវីនៅភាំងនៅមាត់ទ្វារព្រោះមិនយល់ខ្លួនឯងថា ហេតុអ្វីមិនរត់ចេញ មកឈរទ្រាំមើលគេញញឹមដូចធម្មតា?

នាងសួរខ្លួនឯងថា នាងបានលង់ស្រឡាញ់គេតាមរយៈយល់សប្តិទេដឹង? នេះនាងកំពុងយល់សប្តិលើឡានឈ្នួលដដែលទេដឹង?

«ខ្ញុំជិតឆ្កួតហើយ!» នាងគិត។

គេទទួលយកកាបូបនិងវ៉ាលិសរបស់កុសុមាចូលទៅ ឯនាងក៏ដើរតាមទៅដូចពីរនាក់គេពិតជាគូស្នេហ៍គ្នាពិតៗ...

«សាវរិទ្ធិរស់នៅម្នាក់ឯង ឬក៏យ៉ាងម៉េច?»

«ពីរនាក់ប្រពន្ធខ្ញុំ!»

«ឯណាភរិយា?!»

«កំពុងសួរខ្ញុំនេះហើយ!»

មិនដឹងថាហេតុអីបានជានាងទន់ចិត្តល្អកជាមួយគេ ស្នាមញញឹមនិងភាពស្និទ្ធស្នាលរបស់គេ។

រឿងដ៏ចម្លែក គឺការញុំាបាយដ៏រ៉ូមែនទិកជាមួយគេនៅយប់នោះ ហើយបន្ទាប់មកក៏គេងជាមួយគ្នាដូចប្ដីប្រពន្ធ មិនមានអ្វីត្រូវប្រកែកឬគិតច្រើនសោះ។

ការថ្នាក់ថ្នមរបស់គេមកលើនាង ដូចគ្នាបេះបិទទៅនឹងមនុស្សប្រុសដែលតែងតែលួងលោមនាងជារៀងរាល់យប់នៅភ្នំពេញ ប៉ុន្តែកុសុមាទទួលអារម្មណ៍ថា ការលួងលោមរួមភេទលើកនេះគឺជាការភិសម័យមែនទែនរវាងមនុស្សនិងមនុស្សមិនមែនជាការយល់សប្ដិនោះទេ។

មិនយូរប៉ុន្មានបេះដូងនាងពិតជាលង់ទៅក្នុងការថ្នាក់ថ្នមរបស់សារ៉ាវិទ្ធ ហើយគិតថានេះគឺជាសេចក្ដីស្នេហាថ្មីមួយដើម្បីកំដរជីវិតរបស់នាង នាងមិនគួរបន្តចាំអតីតកាល និងមានៈដើរឆ្លងកាត់នូវរឿងខកចិត្ត សោកស្ដាយអ្វីជាមួយនឹងប្រុសសារ៉ាទៀតទេ។

បន្ទាប់ពីរាត្រីដ៏មានសុភមង្គល នាងបានលង់លក់ដោយគ្មានខ្វល់ខ្វាយអ្វីទាំងអស់លើទ្រូងគេ។

ព្រលឹមឡើងគេបាននិយាយថា គេអាចបញ្ជូននាងត្រលប់ទៅភ្នំពេញវិញ ប្រសិនបើនាងចង់ ឬមួយក៏នៅទីនេះបន្តជាមួយគេ ឬឱ្យគេចូលសួរនាងដល់ផ្ទះ។ ដូច្នេះហើយកុសុមានិយាយប្រាប់គេថានាងនឹងស្នាក់នៅទៀតមើលចិត្តគេសិន មុនពេលសម្រេចចិត្តពីអនាគត។

«ហេតុអីបានជារស់នៅម្នាក់ឯង!»

គេថា គេមិនចូលចិត្តមនុស្សច្រើនទេ។ ឪពុកម្ដាយរបស់គេស្នាក់នៅផ្ទះផ្សេងមួយទៀតនៅជាយខេត្តកំពង់ចាម។

យប់ទីពីរនោះ ពួកគេបានបន្តរួមរស់នៅជាមួយគ្នាយ៉ាងផ្អែមល្ហែមជាងយប់ទីមួយទៅទៀត ពីព្រោះតែតយល់ចិត្តគ្នាជាងមុន។

បន្ទាប់ពីហត់នឿយងោកងុយនាងក៏លក់មួយភាំង។

ពេលឮសំឡេងប្រេះប្រោះ នាងដឹងខ្លួនឡើងនិងធុំក្លិនឈ្ងៀម។

កុសុមាងាកមករកគូស្នេហ៍ក៏ឃើញគេងស្កប់ស្កល់ នាងឆ្ងល់ខ្លាចមានអគ្គីភ័យសារ៉ាវិទ្ធិមិនដឹង ក៏ក្រោកឡើងទៅពិនិត្យ។

ពីលើបង្អួចជាន់នេះទៅ ស្រីខំសម្លឹងទៅជាន់ខាងក្រោមព្រោះនោះជាប្រភពក្លិននិងផ្សែង។ នាងឃើញមនុស្សពីរបីនាក់កំពុងសែនព្រេន។

«មើលអីប្រពន្ធសម្លាញ់!»

គេសួរមកពីក្រោយខ្នង។

«អូនធុំក្លិនឈៀម!»

«គេដុតសម្រាមទេ!»

ដៃគេមកដល់ហើយក៏មកឱបចង្កេះនាងយ៉ាងណែន។ មិនដឹងថា តើសាវរិទ្ធគេចុះមកពីគ្រែយ៉ាងម៉េចបានស្រាលនិងរហ័សយ៉ាងនេះទេ។

«ម៉េចពួកគេមកសែនអីនៅឯណោះទាំងកណ្ដាលយប់?»

«មិនដឹង និងមិនខ្វល់ជាមួយអ្នកណាយូរមកហើយ! បងមិនដឹងថាត្រូវខ្វល់ជាមួយពួកគេធ្វើអីទេពេលនេះក្ដី! យើងមានសេចក្ដីសុខហើយហ្នឹង!»

គេនិយាយជាមួយនាងបែបនេះហើយលូកដៃបបោសអង្អែលលើរាងកាយរបស់នាងពីលើដល់ក្រោម ធ្វើសាជាថ្មីនាងស្រើបស្រាលលង់ទៅក្នុងសេចក្ដីស្នេហាដែលមានតែពីរនាក់។

មនុស្សមានទុក្ខស្រាប់តែវាសនាបានឱ្យមករស់នៅបែបនេះជាមួយមនុស្សប្រុសសង្ហាមានអ្វីគ្រប់យ៉ាងម្នាក់ នាងសឹងមិនបាច់ទាំងព្រួយអ្វីពីការងារចិញ្ចឹមជីវិតផងមានអីត្រូវគិតច្រើនទៀត?

នាងក៏តាំងចិត្តទុកឱកាសមួយសម្រាប់ខ្លួនឯងនិងគេសាងជីវិតជាមួយគ្នា។

រហូតដល់ថ្ងៃមួយ នាងចេញមកមុខផ្ទះក៏ឃើញមានបាយសាច់ជ្រូកហើយនិងផ្លែឈើដែលចិតហើយដាក់ក្រាលសែននឹងដី។

ភ្លាមនោះពេលចូលក្នុងផ្ទះវិញក៏បានឃើញនៅលើតុបាយ ដែលសាវរិទ្ធិតែងតែជាអ្នករៀបចំបាយទឹករាល់ដង គឺមានទាំងនំអាកោផ្លែឈើចិតស្រាប់ និងបាយសាច់ជ្រូក។

គ្រប់យ៉ាង ដូចអ្វីដែលកុសុមាបានឃើញនៅលើកម្រាលសំណែនខាងក្រៅដូចគ្នា?

«តស់ញ៉ាំបាយអូនសម្លាញ់!»

នាងភ័យញាក់ក្នុងចិត្ត។

ហេតុអីបានជាគ្រឿងសំណែននៅខាងក្រៅនិងរបស់ដែលនៅលើតុដូចគ្នាបេះបិទ?

នាង រស់នៅទីនេះមួយរយៈហើយម៉េចក៏មិនដែលឃើញសាច់ញាតិរបស់គេ?

តើគេធ្វើការងារអីហេតុអីបានជាគេមិនទៅណាសោះគិតពីនៅផ្ទះ រួមរក្សស្នេហាជាមួយនឹងនាង?

ហេតុអីបានជា នាងមានអារម្មណ៍ថាខ្លួនឯងប្លែកៗ វិលវល់មិនទទួលបានព័ត៌មានអីសោះ?

នាងចាប់ផ្ដើមឆ្ងល់...គេទាញកៅអីឱ្យនាងអង្គុយដូចរាល់ដង។

ពេលនោះហើយនាងចាប់ផ្ដើ លបសម្លឹងទៅក្នុងកញ្ចក់ឯជ្រុងខាងកើត ដោយបួងសួងថា

«សុំឱ្យខ្ញុំដឹងការពិតទាំងអស់នៅទីនេះត្រឹមថ្ងៃនេះ!»

នៅក្នុងកញ្ចក់នៃផ្ទះនេះ បានធ្វើឱ្យកុសុមាចាប់ផ្ដើមបះសក់ជ្រោង ព្រោះមិនឃើញរូបគេហើយក៏មិនឃើញរូបនាងដែរ។

អ្វីៗនៅជុំវិញនេះ ដែលនាងឃើញនៅខាងក្រៅគឺមិនដូចគ្នា។ ក្នុងកញ្ចក់គឺទទេស្អាត គ្រាន់តែជាផ្ទះមួយពោរពេញទៅដោយសំបុកពីងពាង។ នៅលើតុមួយនេះគគ្រិចពោរពេញទៅដោយកណ្ដុរកន្លាត មិនមានអាហារដូចដែលនាងធ្លាប់ឃើញខាងក្រៅកញ្ចក់ឡើយ។

កុសុមាចាប់ផ្ដើមភ័យស្លន់បិទភ្នែករត់ទៅរកទ្វារ។ នាងរត់លឿនណាស់ រត់! រត់! រត់រហូតអស់តែដួលត្មោលសន្លប់។

ភ្ញាក់ខ្លួនឡើងក៏ឃើញខ្លួនឯងនៅទ្វារផ្ទះនៅឯស្រុកកំណើត។

ម្ដាយនាងនិងមនុស្សជាច្រើនទៀតទៅខាងក្នុងផ្ទះកំពុងតែធ្វើពិធីអ្វីម្យ៉ាង នៅចំពោះមុខរូបថតរបស់កុសុមាតែម្ដង។

ពេលនោះហើយដែលនាងដឹងថា នាងមិនមែនជាមនុស្សទៀតទេ នាងគឺជាវិញ្ញាណ ។

នៅក្បែរខ្លួននាងគឺសាវរិទ្ធ។ គេមកដល់ទីនេះ ហើយថែមទាំងអង្វរនាងថា

«ប្រពន្ធសម្លាញ់ទៅផ្ទះយើងវិញ!»

នាងបានសួរទៅសាវរិទ្ធទាំងទឹកភ្នែកថា យើងទាំងពីរជាខ្មោចមែនទេ សាវរិទ្ធិប្រាប់វិញថាទាល់តែជាខ្មោចទើបអាចមើលគ្នាឃើញ តាមពិតសាវរិទ្ធបានស្លាប់តាំងពីច្រើនឆ្នាំមកហើយ គេនៅតែតាមមករកគូស្នេហ៍ដែលគេចងចាំជានិច្ច។

នៅថ្ងៃដែលសុខធនបានរៀបការចោល កុសុម៉ាបានសម្លាប់ខ្លួនឯងនៅក្នុងផ្ទះជួល ឬមិនអាចទទួលយកការខូចចិត្តនេះបាន។

កាលពីនៅក្មេងនាងបាននិយាយថា សាវ៍រិទ្ធិនឹងបាននាងលុះណាតែនាងស្លាប់! ផ្កាប្រទាក់ឈាមជាផ្ការបស់គេ!